**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៧. អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២៩៦/០៨ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីការរៀបចំធ្វើការជំរឿន ទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល ស.វ.

## សម្រេច

**មាត្រា១.-**

កំណត់កាលបរិច្ឆេទសម្រាប់ដំណើរការធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា នៅម៉ោងសូន្យ ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៨ ។

**មាត្រា២.-**

បង្កើតគណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (០១រូប) | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី (០១រូប) | សមាជិក |
| ៤- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (០១រូប) | សមាជិក |
| ៥- រដ្ឋលេខាធិការ ក្រសួងការពារជាតិ (០១រូប) | សមាជិក |
| ៦- រដ្ឋលេខាធិការ ក្រសួងផែនការ (០១រូប) | សមាជិក |
| ៧- រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា (០១រូប) | សមាជិក |
| ៨- រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (០១រូប) | សមាជិក |
| ៩- រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (០១រូប) | សមាជិក |
| ១០- រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ (០១រូប) | សមាជិក |
| ១១- រដ្ឋលេខាធិការ ក្រសួងសុខាភិបាល (០១រូប) | សមាជិក |
| ១២- រដ្ឋលេខាធិការ ក្រសួងព័ត៌មាន (០១រូប) | សមាជិក |
| ១៣- រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី (០១រូប) | សមាជិក |
| ១៤- រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (០១រូប) | សមាជិក |
| ១៥- រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ (០១រូប) | សមាជិក |
| ១៦- អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | លេខាធិការ ។ |

**មាត្រា៣.-**

គណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា មានភារកិច្ច ÷

ក- ណែនាំ និងអនុម័តរាល់កិច្ចការទូទៅ ដែលពាក់ព័ន្ធក្នុងការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ..។

ខ- រៀបចំ និងបង្កើតគណៈកម្មការបច្ចេកទេសធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា មួយមានទីស្នាក់ការនៅក្រសួងផែនការ និងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ

គ- រៀបចំ និងបង្កើតគណៈកម្មាធិការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រគ្រប់ខេត្ត ក្រុង

ឃ- តែងតាំងមន្ត្រីឱ្យចូលរួមធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ

ង- ប្រជុំការងារតាមរបបប្រជុំមួយខែម្តង តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន

ច- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅ និងលទ្ធផលក្នុងការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

**មាត្រា៤.-**

គណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥.-**

ការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ នឹងរាប់បញ្ចូលនូវ ÷

១- កិច្ចប្រតិបត្តិការដំបូងរបស់ការធ្វើជំរឿនមាន ÷

ក. ការរៀបចំផែនទី

ខ. ការរាប់ និងចុះបញ្ជីលំនៅឋាន

គ. ការធ្វើអង្កេត និងធ្វើជំរឿនសាកល្បង

២- ការធ្វើសម្ភាសន៍សម្រាប់ការធ្វើជំរឿន

៣- កិច្ចប្រតិបត្តិការចុងក្រោយរបស់ការធ្វើជំរឿនមាន ÷

ក. ការធ្វើអង្កេតសម្រាប់វាយតម្លៃលើការធ្វើជំរឿនដែលបានធ្វើហើយ

ខ. ការធ្វើអង្កេតផ្សេងទៀត ក្នុងករណីចាំបាច់ ។

**មាត្រា៦.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអគ្គនាយកនៃការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ និង ៤.ៗ

ត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ទីរផែនការខេត្តក្រុង ជួយរាល់ការងារក្នុងការធ្វើជំរឿន ។

**មាត្រា៧.-**

មន្ត្រីបំពេញការងារជំរឿនរួមមាន អ្នកសម្ភាសន៍ស្រង់យកព័ត៌មាន អ្នកត្រួតពិនិត្យការសម្ភាសន៍ និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការធ្វើជំរឿន ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់អគ្គនាយកនៃការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។ ការចាត់ចែងនេះអនុវត្តបានតែក្នុងអំឡុងពេលធ្វើជំរឿនតែប៉ុណ្ណោះ ។

**មាត្រា៨.-**

រដ្ឋមន្ត្រីក្រសួងផែនការមានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងជនសាមញ្ញ ដើម្បីសហការជួយធ្វើកិច្ចការជំរឿនទូទៅនូវប្រជារាស្ត្រ ។

**មាត្រា៩.-**

ត្រូវធ្វើជំរឿនជនគ្រប់រូបដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា វៀរលែងតែសមាជិកអង្គទូតបរទេស និងក្រុមជនដូចគ្នានឹងអង្គទូតដែរ តាមកិច្ចព្រមព្រៀងដែលត្រូវកំណត់ឡើងជាមួយនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា១០.-**

ម្ចាស់លំនៅឋានគ្រប់ប្រភេទ និងអ្នកគ្រប់គ្រងទីកន្លែងនានា ត្រូវអនុញ្ញាតឱ្យមន្ត្រីបំពេញការងារជំរឿនបានចូលលំនៅឋាន ឬទីកន្លែងរបស់ខ្លួន ក្នុងគោលដៅនៃការធ្វើជំរឿន និងអនុញ្ញាតឱ្យមន្ត្រីទាំងនោះបានលាបពណ៌ បិទអក្សរ បិទសញ្ញាឬលេខសម្គាល់នៅតាមកន្លែងចាំបាច់សម្រាប់បម្រើដល់ការងារធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

**មាត្រា១១.-**

រដ្ឋមន្ត្រីក្រសួងផែនការអាចប្រកាសតែងតាំងអ្នកគ្រប់គ្រង តាមទីកន្លែងដែលមានលក្ខណៈពិសេស ធ្វើសម្ភាសន៍អ្នកនៅក្នុងរង្វង់គ្រប់គ្រងរបស់ខ្លួន ។

អ្នកគ្រប់គ្រងតាមទីកន្លែងពិសេសទាំងនោះមាន ៖

ក. មេបញ្ជាការយោធា នគរបាល ដែលគ្រប់គ្រងនៅតាមអង្គភាពប្រមូលផ្តុំ ។

ខ. នាយនាវា ដែលគ្រប់គ្រងនៅតាមនាវារបស់ខ្លួន ។/.

គ. នាយកមន្ទីរពេទ្យសាធារណៈ និងឯកជន នាយកពន្ធនាគារ នាយកមណ្ឌលអប់រំកែប្រែ នាយកមជ្ឈមណ្ឌលសង្គ្រោះ នាយកគ្រឹះស្ថានអប់រំដែលមានមនុស្សរស់នៅប្រមូលផ្តុំ ហើយនិងចៅអធិការវត្ត អ្នកគ្រប់គ្រងវិហារសាសនានានា ។

ឃ. អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌលសម្រាកកាយ ។

ង. អ្នកចាត់ការខ្សែរថភ្លើង អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុងគ្រឹះស្ថានឧស្សាហកម្ម ។

**មាត្រា១២.-**

មន្ត្រីដែលគ្មានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅ បញ្ជី ឬសំណៅគត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ ។

**មាត្រា១៣.-**

ថវិកាក្នុងការរៀបចំធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវស្ថិតក្នុងគម្រោងថវិកាជាតិ ។

រដ្ឋមន្ត្រីក្រសួងផែនការត្រូវគ្រោងទុក និងចាត់ចែងប្រើប្រាស់ថវិកាជាតិ ឬថវិកាជំនួយអន្តរជាតិសម្រាប់កិច្ចការនេះ ។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងសមាជិកគណៈកម្មាធិការជាតិ ដូចក្នុងមាត្រា២ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ល.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- ឯកសារ-កាលប្បវត្តិ